# អាទិត្យទី២២នៃរដូវធម្មតា
# កសិដ្ឋានឋានសួគ៌ភ្នំវល្លិ៍
# ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១
# “យើងជាកំពូលនៃការបង្កើត”

បងប្អូនជាទីស្រឡាញ់!
ថ្ងៃនេះ ដែលខ្ញុំបានមកដល់កសិដ្ឋានឋានសួគ៌ភ្នំវល្លិ៍ ដែលមានភ្នំ មានដើមស្វាយ មានម្រេចកំពត មានដើមឈើគ្រប់មុខ និងសត្វគ្រប់ប្រភេទ។ ដូច្នេះ ពេលយើងមកដល់ទីនេះណែនាំឱ្យយើងនឹកឃើញដល់ព្រះជាម្ចាស់ដែលបានបង្កើតអ្វីៗទាំងអស់។ ពីដើមរៀងមក ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្កើតទាំងផែនដី ទាំងផ្ទៃមេឃ ទាំងផ្កាយ ទាំងព្រះអាទិត្យ ទាំងព្រះច័ន្ទ។ ពីដើមរៀងមក ព្រះជាម្ចាស់បានបង្កើតធម្មជាតិទាំងឡាយ មានដើមឈើ មានផ្កា មានសត្វ...។ នៅក្នុងកសិដ្ឋានរបស់យើងមានសត្វទា សត្វគោ សត្វមាន់ សត្វពពែ សត្វជ្រូក សត្វសេះ យើងក៏មានសត្វពស់ដែរ ដូចនៅក្នុងសួនអេដែនពីដើមក៏មានសត្វពស់។

កំពូលដែលយើងបានស្តាប់ថ្ងៃនេះនៅក្នុងព្រះបន្ទូលដំណឹងល្អ “**ព្រះអង្គសព្វព្រះហឫទ័យបង្កើតយើងមក ដោយសារព្រះបន្ទូលនៃសេចក្តីពិត ដើម្បីឱ្យយើងទៅជាផលដំបូងម្យ៉ាងនៃអ្វីៗទាំងអស់ដែលព្រះអង្គបង្កើតមក**”។ បងប្អូនជាទីស្រឡាញ់ នៅពេលយើងនឹកឃើញរបៀបដែលព្រះជាម្ចាស់បានបង្កើតពិភពលោក របៀបដែលព្រះជាម្ចាស់បានបង្កើតសត្វលោក យើងយល់ថាយើងជាកំពូលនៃការបង្កើត។ នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះអង្គមានព្រះបន្ទូលថា “**ខ្ញុំបង្កើតបុរសនិងស្ត្រីឱ្យមានលក្ខណៈដូចយើង ឱ្យទៅជាតំណាងយើង**”។ នេះជាអ្វីដែលយើងបានទទួលនៅក្នុងជីវិតរបស់យើង យើងដឹងថាព្រះជាម្ចាស់បានបង្កើតយើងជាបុរស ជាស្ត្រី ជាតំណាងនៃព្រះជាម្ចាស់លើផែនដីនេះ ដើម្បីណែនាំឱ្យយើងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានបង្កើតយើង។ “**ចូរប្រព្រឹត្តតាមព្រះបន្ទូល កុំគ្រាន់តែស្តាប់តាមបញ្ញា ប៉ុន្តែសូមធ្វើតាមព្រះបន្ទូលនេះនៅក្នុងជីវិតប្រចាំថ្ងៃ**”។

ថ្ងៃនេះ ព្រះយេស៊ូចង់និយាយថាកុំលាងដៃកុំលាងតុ ដោយសារពេលយើងស្ដាប់អត្ថបទនេះហើយ ប្រហែលយើងមានអារម្មណ៍ថា សាវ័ករបស់ព្រះយេស៊ូឥតមានអនាម័យ។ ជាពិសេសនៅក្នុងសម័យកូវីដ-១៩នេះ យើងដឹងថាអនាម័យសំខាន់ណាស់លាងចាន លាងតុ លាងគ្រប់ទីកន្លែងមុនយើងចេញចូល។ នេះជាអ្វីដែលសំខាន់ ហើយព្រះយេស៊ូមិនប្រឆាំងនឹងអនាម័យទេ កុំឱ្យយើងយល់ច្រឡំ។ ក៏ប៉ុន្តែ ព្រះយេស៊ូចង់បង្ហាញថាយើងពូកែនិយាយណាស់ យើងពូកែនិយាយថាយើងត្រូវការធ្វើនេះ ត្រូវការធ្វើនោះ ត្រូវការធ្វើតាមច្បាប់ តាមវិន័យ...។ ប៉ុន្តែ ចុងក្រោយយើងធ្វើតែកាយវិកាយខាងក្រៅ តែចិត្តរបស់យើងនៅខ្ទោងងឹត ព្រះបន្ទូលដែលបានបង្កើតយើងគឺពិតជាបានបង្កើតយើងមែន ប៉ុន្តែមិនបានយាងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង ដើម្បីឱ្យយើងអនុវត្ត។ យើងពូកែនិយាយដោយបបូរមាត់របស់យើង យើងពូកែបញ្ជា យើងពូកែបង្គាប់ យើងពូកែអប់រំគេ ប៉ុន្តែអ្វីដែលសំខាន់បំផុតនេះជាអ្វីដែលព្រះយេស៊ូចង់បង្ហាញឱ្យយើងយល់ថ្ងៃនេះ គឺនៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ យើងត្រូវតែរស់នៅតាមព្រះបន្ទូលដែលព្រះជាម្ចាស់បានបង្កើតតាមព្រះបន្ទូលដែលព្រះជាម្ចាស់បានប្រទានឱ្យយើង។

យើងបានទទួលអំណោយទានយ៉ាងច្រើន យើងជាពូជមួយយ៉ាងពិសេស ដែលត្រូវការណែនាំឱ្យយើងមានផ្លែយ៉ាងច្រើននៅក្នុងជីវិត។ មិនមែនតែដើមស្វាយ មិនមែនតែដើមស្រកានាគ មិនមែនតែដើមម្រុំ... ប៉ុន្តែជាមនុស្សយើង។ ផ្កានិងផ្លែ អាចចេញលុះត្រាតែយើងរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលយើងបានទទួលនៅថ្ងៃយើងជ្រមុជទឹក ដែលយើងបានទទួលពីមួយថ្ងៃទៅមួយថ្ងៃនៅពេលយើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ **តើព្រះបន្ទូលនេះណែនាំជីវិតរបស់យើងដូចម្ដេច?** នៅក្នុងរដូវកូវីដ-១៩នេះ យើងសង្ឃឹមថាបន្តិចទៀតយើងនឹងផុតឆាប់ៗ យើងមានឱកាសច្រើនដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ កុំនិយាយថា យើងចូលព្រះវិហារមិនបានយើងក៏ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបាននោះទេ ព្រះជាម្ចាស់មានព្រះបន្ទូលជានិច្ចមិនមែនតែនៅក្នុងព្រះវិហារ។ ប៉ុន្តែ ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈបងប្អូនឯទៀតៗ ព្រះជាម្ចាស់មានព្រះបន្ទូលដល់យើងតាមហ្វេសបុក តាមប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ជាពិសេសតាមរយៈហ្វេសបុកភេច LIVE Catholic Channel ជារៀងរាល់ថ្ងៃយើងមានឱកាសដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជារៀងរាល់ថ្ងៃខ្ញុំបានបង្ហោះវីដេអូ ២នាទីសម្រាប់ស្មារតីយើង ២នាទីដើម្បីឱ្យយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឱ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់បន្តិចម្ដងៗកែប្រែចិត្តគំនិតរបស់យើង។ ដោយសារយើងមិនអាចកែលឿនៗបានទេ យើងមានមួយជីវិតដើម្បីកែប្រែ ប៉ុន្តែយើងត្រូវតែយកចិត្តទុកដាក់ ដោយសារយើងបានទទួលព្រះអំណោយទានដ៏ល្អពិសេសពីព្រះជា

ម្ចាស់។ គ្រប់អំណោយដ៏ល្អពិសេស និងអ្វីៗទាំងប៉ុន្មានដ៏គ្រប់លក្ខណៈដែលយើងបានទទួល សុទ្ធតែមកពីស្ថានលើទាំងអស់ គឺមកពីព្រះបិតាដែលបានបង្កើតពន្លឺ ដែលបានបង្កើតមនុស្សយើង។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះជាពេលវេលាដើម្បីអនុវត្ត យើងមានឧទាហរណ៍យ៉ាងជាក់ស្តែង ថ្ងៃនេះលោកយ៉ាកុបនិយាយច្បាស់មែនទែន "**គឺស្ថិតនៅលើការជួយឧបត្ថម្ភក្មេងកំព្រា និងស្ត្រីមេម៉ាយ**"។ ប៉ុន្មានដងនៅក្នុងសម្ព័ន្ធមេត្រីចាស់ ប៉ុន្មានដងនៅក្នុងសម្ព័ន្ធមេត្រីថ្មីយើងបានស្តាប់អំពីការស្វាគមន៍ជនបរទេស ជួយកុមារកំព្រានិងស្ត្រីមេម៉ាយ។ នេះដោយសារ ជាមនុស្សដែលបាត់បង់ទីពឹង ជនបរទេសដែលបានចេញពីប្រទេសកំណើតរបស់ខ្លួន ដើម្បីទៅប្រទេសមួយទៀត។ ជាក់ស្តែងនៅប្រទេសអាហ្គានីស្ថានសព្វថ្ងៃ ក្នុងរយៈពេលតែ២សប្តាហ៍មានជាង១២ម៉ឺននាក់ដែលបានចាកចេញពីប្រទេសនេះ ដើម្បីទៅប្រទេសផ្សេងៗ ដោយសារគេភ័យខ្លាចសម្រាប់ជីវិតផ្ទាល់ខ្លួននៅក្នុងស្ថានភាពនយោបាយថ្មី។ **តើប្រទេសនីមួយៗចេះទទួលស្វាគមន៍គេឬទេ?** គេបាត់បង់ផ្ទះ បាត់បង់គ្រួសារមួយចំនួន គេទៅដល់កន្លែងថ្មីមួយដែលគ្មានទីពឹង ដែលមិនស្គាល់វប្បធម៌...។ ជាមូលហេតុ ជនបរទេសជានិមិត្តរូបនៃមនុស្សដែលយើងត្រូវតែទទួលស្វាគមន៍ជានិច្ច។ ស្ត្រីមេម៉ាយ កុមារកំព្រា ជាមនុស្សដែលបាត់បង់ទីពឹង បាត់បង់ភាពកក់ក្តៅដ៏សំខាន់បំផុតនៅក្នុងជីវិត គឺឪពុកម្តាយ គឺគ្រួសារផ្ទាល់ខ្លួន នេះជាមូលហេតុជាក្រុមមនុស្សដែលយើងត្រូវតែជួយ។ ប៉ុន្តែ ដោយដឹងថាមនុស្សទាំងអស់ ចាស់ជរា អ្នកជំងឺ ដែលគ្មានទីពឹងជាអាទិភាពសម្រាប់យើងជួយ។ ដូច្នេះ យើងមិនចេះតែនិយាយដោយមិនធ្វើ ថ្ងៃនេះយើងយល់ ថ្ងៃនេះយើងយកចិត្តទុកដាក់ធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ប៉ុន្តែ សូមចាប់អារម្មណ៍នៅពេលនោះលោកយ៉ាកុបមិននិយាយអំពីតែស្ត្រីមេម៉ាយ កុមារកំព្រា គាត់បានថែមថា "**ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនឱ្យផុតពីអំពើសៅម៉ងរបស់លោកិយនេះ**"។ តាមពិត យើងមិនតែគិតដល់បងប្អូនឯទៀតៗយើងត្រូវការគិតដល់យើងផ្ទាល់ខ្លួនដែរ យើងត្រូវការគិតដល់ជីវិតរបស់យើងដែរ ដល់សុខភាពរបស់យើង ដល់កម្លាំងកាយកម្លាំងចិត្តរបស់យើង។ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "**អំពើសៅម៉ងមិនចូលនៅក្នុងខ្លួនយើង ផ្ទុយទៅវិញចេញពីដួងចិត្តរបស់យើង**" អំពើមិនបរិសុទ្ធមិនចូលនៅក្នុងខ្លួនរបស់យើង ប៉ុន្តែចេញពីខ្លួនយើង។ ដោយសារមនុស្សយើងពីដើមរៀងមក អំពើអាក្រក់បានចូលនៅក្នុងខ្លួនមនុស្សដោយសារយើងមានចិត្តលោភលន់ ដោយសារយើងមានចិត្តច្រណែន។ ចិត្តលោភលន់និងចិត្តច្រណែន ជាមូលដ្ឋាននៃអំពើឃោរឃៅទាំងអស់ដែលយើងអាចប្រព្រឹត្ត អំពើនេះមិនមែនមកពីព្រះជាម្ចាស់ទេគឺមកពីមនុស្សយើងបង្កើតខ្លួនឯងនៅក្នុងសេរីភាពរបស់យើង។

ដូច្នេះ ថ្ងៃនេះពិតមែនយើងអធិដ្ឋានដើម្បីឱ្យយើងរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងបង្កើតផលផ្លែយ៉ាងច្រើនដូចស្មៅខៀវខ្ចីនៅជុំវិញខ្ញុំ ដើម្បីឱ្យយើងមានផ្កាយ៉ាងច្រើន។ សូមចាប់អារម្មណ៍ដើមស្វាយយើងគ្មានផ្កា តែដើមស្វាយគេមានផ្កា នេះដោយសារដើម្បីស្វាយយើងជាដើមស្វាយធម្មជាតិ។ ដូចមនុស្សយើង ព្រះជាម្ចាស់បានបង្កើតយើងឱ្យយើងទៅជាមនុស្សដែលរស់នៅក្នុងជីវិតធម្មតាដែលព្រះជាម្ចាស់បានរៀបចំ។ ដើមស្វាយគេមានផ្កាពេញ ខ្លះចាប់ផ្តើមចេញផ្លែដោយសារគេបាញ់ថ្នាំ ដែលព្រះជាម្ចាស់មិនចង់ឱ្យមនុស្សយើងបាញ់ថ្នាំដើម្បីធ្វើជាមនុស្សល្អ។ ព្រះជាម្ចាស់ចង់ឱ្យមនុស្សយើងរៀបចំខ្លួន ឱ្យអ្វីៗទាំងអស់ដែលចេញពីខ្លួនរបស់យើងទៅជាអំពើល្អ អំពើត្រឹមត្រូវដើម្បីណែនាំឱ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់មានគ្រប់ទីកន្លែងនៅលើផែនដីនេះ។ ដូច្នេះ យើងបន្តអធិដ្ឋានដើម្បីឱ្យយើងរួមគ្នាកសាងព្រះសហគមន៍របស់យើង ទោះបីនៅក្នុងស្ថានភាពកូវីដ-១៩ក៏ដោយ យើងដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង ព្រះជាម្ចាស់បំភ្លឺយើង ព្រះជាម្ចាស់ណែនាំឱ្យយើងទៅជាមនុស្សដ៏ពេញលក្ខណៈដោយសារព្រះជាម្ចាស់បានបង្កើតយើង។ យើងជាកំពូលនៃព្រះបន្ទូលរបស់ព្រះអង្គ យើងជាកំពូលនៃការបង្កើតលើផែនដីនេះ។ សូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដើម្បីឱ្យយើងរកផ្លូវធ្វើជាសាវ័ករបស់ព្រះអង្គ ធ្វើជាសាក្សីនៃព្រះពន្លឺដែលព្រះអង្គបានបង្កើតនៅលើផែនដីនេះ។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ឝ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ